NEWS RELEASE

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# កម្ពុជា៖ ក្រុមអ្នកជំនាញ អ.ស.ប សម្តែងកង្វល់អំពីសេរីភាពសារព័ត៌មាន នៅមុនការបោះឆ្នោត

ទីក្រុងហ្សឺណែវ (១៥ មិថុនា ២០១៨) - ក្រុមអ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប បានអំពាវនាវដល់អាជ្ញាធរកម្ពុជាឲ្យគោរព និងធានាសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិយោបល់ ដោយសម្តែងកង្វល់អំពីការបង្ក្រាបប្រព័ន្ធផ្សព្វផ្សាយនៅមុនការបោះឆ្នោតជាតិ នៅថ្ងៃទី២៩ ខែកក្កដា។

កាលពីខែមុន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានចេញក្រមសីលធម៌ប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការបោះឆ្នោត ដោយហាមប្រាមមិនឲ្យចុះផ្សាយព័ត៌មានដែលអាចនាំឲ្យមានការភាន់ច្រឡំ និង/ឬបាត់បង់ទំនុកចិត្តក្នុងការបោះឆ្នោត ដោយធ្វើការផ្សាយព័ត៌មានដែលរារាំងប្រជាពលរដ្ឋមិនឲ្យបោះឆ្នោត និងបញ្ចេញមតិផ្ទាល់ខ្លួន ឬបុរេនិច្ឆ័យ។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "ការហាមប្រាមប្រព័ន្ធផ្សព្វផ្សាយក្នុងក្រមសីលធម៌នេះ បាននាំឲ្យមានកង្វល់ជាខ្លាំងអំពីសេរីភាពសារព័ត៌មាន"។ "ការហាមឃាត់ទាំងនេះ ប្រើពាក្យពេចន៍ក្នុងន័យទូលាយ និងមិនច្បាស់លាស់ដែលអាចនាំឲ្យមានការរឹតត្បិតលក្ខណៈទូលំទូលាយលើប្រព័ន្ធផ្សព្វផ្សាយ ដែលអាចមិនស្របទៅនឹងបទដ្ឋានអន្តរជាតិ។"

"អ្នកសារព័ត៌មានមានទំនួលខុសត្រូវ ក្នុងការធ្វើសេចក្តីរាយការណ៍អំពីបញ្ហាទាំងឡាយដែលកើតមាននៅមុនពេលបោះឆ្នោត ជាពិសេស បញ្ហាចម្រូងចម្រាសនានា។ ការរាយការណ៍បែបនេះ គឺជាផ្នែកមួយដ៏សំខាន់នៃការរាយការណ៍ព័ត៌មានដែលមានតម្លាភាព និងមានទំនួលខុសត្រូវ នៅក្នុងអំឡុងពេលបោះឆ្នោត។ ការរាយការណ៍នេះជួយដល់អ្នកបោះឆ្នោតឲ្យធ្វើការជ្រើសរើស ដោយបានទទួលព័ត៌មានគ្រប់គ្រាន់។"

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "ការហាមប្រាមនេះក៏មានផលប៉ះពាល់អវិជ្ជមានផងដែរ ទៅលើសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងការជួបប្រជុំដោយសន្តិវិធី ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការចូលរួមជាសាធារណៈក្នុងបរិបទនៃការបោះឆ្នោត។"

ការហាមប្រាមរបស់ គ.ជ.ប មានលក្ខណៈស្រដៀងគ្នាទៅនឹងការហាមប្រាម ដែលបានធ្វើនៅមុនការបោះឆ្នោត ឃុំ-សង្កាត់ ឆ្នាំ២០១៧។ កង្វល់អំពីការហាមប្រាមនោះ ត្រូវបានកត់សម្គាល់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំចុងក្រោយរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

មេដឹកនាំគណបក្សសង្គ្រោះជាតិ (CNRP) ដែលបានរំលាយ បានអំពាវនាវឲ្យអ្នកបោះឆ្នោតធ្វើពហិការមិនទៅបោះឆ្នោត ឬមិនបោះឆ្នោតឲ្យគណៈបក្សណាមួយ ជាសញ្ញាមួយនៃការតវ៉ា។

ជាការឆ្លើយតប ប្រធាន គ.ជ.ប បានអំពាវនាវឲ្យចាត់វិធានការផ្លូវច្បាប់ទៅលើអ្នកដែលអំពាវនាវឲ្យធ្វើពហិការ។ ប្រធាន គ.ជ.ប បានអះអាងថា ការអំពាវនាវបែបនេះ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ និងបណ្តាលឲ្យមានការភាន់ច្រឡំ នាំឲ្យបាត់បង់ទំនុកចិត្តក្នុងការបោះឆ្នោត។

តាមច្បាប់កម្ពុជា ការបោះឆ្នោតមិនមែនជាកាតព្វកិច្ចទេ។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "ទោះជាការបោះឆ្នោតមានចរិតលក្ខណៈបែបណាក៏ដោយ ក៏ត្រូវតែគោរព និងធានាសិទ្ធិមនុស្សទាំងអស់ដែរ។ យើងលើកទឹកចិត្តដល់អាជ្ញាធរកម្ពុជាឲ្យធានាថា មនុស្សគ្រប់រូបអាចបង្ហាញទស្សនៈនយោបាយ និងមតិផ្សេងៗទៀតរបស់គេដោយសេរី រួមទាំងការជម្រើសមិនបោះឆ្នោតឲ្យគណៈបក្សណាមួយផងដែរ។"

"ទោះជាច្បាប់សិទ្ធិមនុស្សកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហាមប្រាមយ៉ាងត្រឹមត្រូវចំពោះការបំភិតបំភ័យ ឬការគំរាមកំហែងអ្នកបោះឆ្នោតក៏ដោយ ក៏ការអំពាវនាវឲ្យធ្វើពហិការមិនទៅបោះឆ្នោត មិនមែនជាការបង្ខិតបង្ខំ ឬបំភិតបំភ័យឡើយ ហើយការអំពាវនាវនោះទៀតសោតក៏មិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដែរ។ ផ្ទុយទៅវិញ ការអំពាវនេះគឺទុកឲ្យអ្នកបោះឆ្នោតសម្រេចដោយសេរីថាត្រូវចូលរួម ឬមិនចូលរួមបោះឆ្នោត។"

ទាក់ទងនឹងបរិបទទូទៅនៃការបោះឆ្នោតជាតិ អ្នកស្រី រ៉ូណា ស្មីត អ្នកជំនាញឯករាជ្យមួយរូប ដែលត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សតែងតាំងឲ្យឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា កាលពីខែមេសា បានស្នើយ៉ាងទទូចឲ្យរដ្ឋាភិបាលដោះលែងជាបន្ទាន់នូវមេដឹកនាំគណបក្សប្រឆាំងដែលកំពុងស្ថិតក្នុងការឃុំខ្លួននៅឡើយ និងស្នើសុំឲ្យដកចេញនូវបម្រាមលើគណបក្សប្រឆាំងមិនឲ្យចូលរួមក្នុងការបោះឆ្នោតជាតិ នៅថ្ងៃទី២៩ ខែកក្កដា ផងដែរ ដើម្បីធានាលទ្ធិប្រជាធិបតេយ្យពហុបក្សមួយពិតប្រាកដនៅកម្ពុជា។

**ចប់**

*ក្រុមអ្នកជំនាញ៖ សាស្ត្រាចារ្យ រ៉ូណា ស្មីត** (Rhona Smith) អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, **លោក ដេវី កាយេ** (David Kaye) អ្នករាយការណ៍ពិសេសស្ដីពីការលើកស្ទួយ និងការពារសិទ្ធិសេរីភាពនៃគំនិត និងសម្ដែងមតិ, **លោក Clément Nyaletsossi Voulé** អ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម។

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញ ឯករាជ្យ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការឯករាជ្យពីរដ្ឋាភិបាល និង អ.ស.ប។ ពួកគាត់បំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីប្រទេសកម្ពុជា។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រសម្រាប់ប្រទេស៖ កម្ពុជា*

សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗសូមទាក់ទង៖ លោក ម៉ាស៍មូដ ហ្គារហ្គា (Mahmoud Garga) តាមរយៈទូរស័ព្ទលេខ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ ឬ អ៊ីមែល mgarga@ohchr.org) អ្នកស្រី អ៊ីស្ទើរ ឡាំ (Esther Lam) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨៩១០៨ ឬ អ៊ីមែល / srcambodia@ohchr.org)

សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទងនៅទីក្រុងហ្សឺណែវ៖ លោក ហ្សេរ៉េមី ឡូរ៉ង់ស៍ (Jeremy Laurence) សិទ្ធិមនុស្ស អ.ស.ប – អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីមែល jlaurence@ohchr.org)

*ឆ្នាំ២០១៨ នេះ គឺជា**ខួបលើកទី៧០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ដែលអង្គការសហប្រជាជាតិបានអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្តីប្រកាសជាសកលនេះជាប់លំដាប់ថ្នាក់ពិភពលោក ផ្នែកខាងអត្ថបទដែលត្រូវបានបកប្រែជា ៥០០ ភាសា ដោយផ្អែកលើគោលការណ៍គ្រឹះដែលថា "មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាពខាងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ"។ គោលការណ៍គ្រឹះនេះ ស្ថិតនៅជាមួយមនុស្សគ្រប់រូប ជារៀងរាល់ថ្ងៃ។ ដើម្បីគោរពខួបលើកទី៧០ នៃឯកសារដែលមានឥទ្ធិពលដ៏វិសេសវិសាលនេះ និងដើម្បីរក្សាគោលការណ៍នេះកុំឲ្យបាត់បង់ យើងសូមស្នើឲ្យមនុស្សគ្រប់រូបនៅលើពិភពលោក **ក្រោកឈរឡើងដើម្បីសិទ្ធិមនុស្ស៖***

*www.standup4humanrights.org.*